# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះរៀបរាប់ពី សូចនាករនៃសេដ្ឋកិច្ចពិភពលោកសំខាន់ៗ និងសេដ្ឋកិច្ចនៅអាស៊ីខាងត្បូង និងខាងកើត។

កំណើនសេដ្ឋកិច្ចនៅអាស៊ី និងប្រទេសឧស្សាហកម្មមួយចំនួន មានស្ថិរភាពឡើងវិញនៅឆ្នាំ២០១២។ ដូច្នេះការងារនៅសល់ត្រូវបន្តដោះស្រាយ គឺការស្តារឡើងវិញនូវទំនុករបស់អ្នកប្រើប្រាស់ និងវិនិយោគិន ឲ្យដល់កម្រិតនៅមុនពេលមានវិបត្តិ និងខ្ពស់ជាងនោះទៀត។ អាស៊ីនៅតែជាកម្លាំងជំរុញកំណើនក្នុងពិភពលោកបន្តទៀត នៅពេលដែលបណ្តាប្រទេសអភិវឌ្ឍន៍ចម្បងៗកំពុងព្យាយាមងើបឡើងវិញ។

នៅឆ្នាំ២០១២ ផសស ពិត នៅឥណ្ឌូនេស៊ី មានកំណើនជាមធ្យម ៦,០% ទោះបីជាមានការធ្លាក់ចុះបន្តិច ក្នុងត្រីមាសទី៤ ឆ្នាំ២០១២ ដល់ ៦,១% ធៀបនឹង កម្រិត ៦,៥% នៅត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ ផសស នៅម៉ាឡេស៊ីកើន ៦,៤% ធៀបនឹងមួយឆ្នាំមុន រីឯ ផសស នៅសិង្ហបុរី ធ្លាក់កំណើនមកត្រឹម ១,៥% ធៀបនឹង ៣,៦% ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ថៃសម្រេចបានកំណើនប្រចាំឆ្នាំខ្ពស់ណាស់ ដល់ទៅ ១៩,៥% នៅត្រីមាសទី៤ ដោយសារចំណាយប្រើប្រាស់ក្នុងស្រុក និងការនាំចេញកើនឡើងយ៉ាងខ្លាំង។ កំណើននៅចិន ថយចុះ ប៉ុន្តែនៅតែខ្ពស់ដល់ ៧,៩% នៅត្រីមាសទី៤។ ភាពតានតឹងខាងនយោបាយ និងយោធា រវាងចិន និងជប៉ុន លើបញ្ហាកោះតូចៗមួយចំនួន មិនបានធ្វើឲ្យខូចខាតដល់សេដ្ឋកិច្ចចិនទេ ហើយការតាំងចិត្តរបស់ប្រទេសទាំងពីរ ក្នុងការដោះស្រាយជម្លោះដោយសន្តិភាព អាចជះឥទ្ធិពលធ្វើឲ្យកំណើនមានស្ថិរភាព។ នៅត្រីមាសទី៤ កំណើន ផសស ប្រចាំឆ្នាំ នៅហុងកុង ធ្លាក់ចុះមកត្រឹម ២,៥% ធៀបនឹង កម្រិត ៣,០% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន រីឯកំណើន ផសស នៅកូរ៉េ គឺ ១,៦%។

កំណើនក្នុងប្រទេសអ្នកមាន ជាពិសេសនៅតំបន់អឺរ៉ូ នៅតែបន្តឡើងចុះ ដោយសារអន្តរាគមន៍សេដ្ឋកិច្ចមិនបានផ្តល់លទ្ធផលគួរជាទីពេញចិត្ត។ នៅត្រីមាសទី៤ សេដ្ឋកិច្ចតំបន់អឺរ៉ូ បានធ្លាក់ចុះយ៉ាងខ្លាំង ដោយមានកំណើន ផសស អវិជ្ជមាន (-0,៩%) ដល់ទៅ បីត្រីមាសជាបន្តបន្ទាប់ និងកំណើនសូន្យនៅត្រីមាសទី១។ បញ្ហាវិបត្តិធនាគារ បន្តរីករាលដាល ហើយថ្មីៗនេះបានរាលដាលដល់ប្រទេស Cyprus។ កំណើននៅសហរដ្ឋអាមេរិក មានស្ថិរភាពឡើងវិញ ដោយសេដ្ឋកិច្ចមានអត្រាកំណើនប្រចាំឆ្នាំ១,៦%នៅត្រីមាសទី៤និងបានបង្កើតការងារជាច្រើនថែមទៀត។ប៉ុន្តែអ្នកបង្កើតគោលនយោបាយ និងរដ្ឋាភិបាលនៅតែត្រូវចរចាគ្នាដោះស្រាយឲ្យបាននូវ បញ្ហាថវិកាសម្រាប់ឆ្នាំសារពើពន្ធ និងតុល្យភាពថវិកា ដើម្បីរក្សាកំណើនក្នុងរយៈពេលវែង។ ជប៉ុនកំពុងបន្តស្តារ និងកសាងសេដ្ឋកិច្ចឡើងវិញ ប៉ុន្តែកំណើននៅតែបន្តឡើងចុះ។ បញ្ហាបន្ទាន់ៗ រួមមាន កំណើនចំណាយរបស់រដ្ឋាភិបាលទៅលើកម្មវិធីសង្គមកិច្ចសម្រាប់មនុស្សចាស់ជរា កម្មវិធីកសាងឡើងវិញ សម្រាប់តំបន់រងគ្រោះដោយរលកសមុទ្រយក្សស៊ូណាមី និងជម្លោះដែនដីជាមួយ ចិន កូរ៉េខាងត្បូង និងរុស្ស៊ី។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

ក្នុងពេញមួយឆ្នាំ២០១២ អត្រាអតិផរណានៅប្រទេសភាគច្រើន ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ នៅត្រីមាសទី៤ កំណើនថ្លៃសរុបនៅកម្ពុជាធ្លាក់ចុះដល់ ១,៨% ធៀបនឹងកំណើន ៤,៩% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន។ ប៉ុន្តែថ្លៃប្រេងឥន្ធនៈ និងឧស្ម័ន នៅតែខ្ពស់ដដែល ដែលជះឥទ្ធិពលដល់បន្ទុកចំណាយផលិតកម្មរបស់អាជីវកម្មផ្សេងៗ និងកម្រិតជីវភាពរបស់គ្រួសារនានា។ នៅត្រីមាសទី៤ អតិផរណានៅវៀតណាមធ្លាក់ចុះដល់ ៧,០% ធៀបនឹង អត្រា ១៩,៨% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន។ កំណើនកម្រិតថ្លៃសរុប បណ្តាលជាសំខាន់មកពី ការដាក់អនុវត្តកញ្ចប់លើកទឹកចិត្តរបស់រដ្ឋាភិបាលដើម្បីសម្រាលការប៉ះទង្គិចពីខាងក្រៅ។ នៅត្រីមាសទី៤ អតិផរណានៅចិន ធ្លាក់ចុះដល់ ២,១% ធៀបនឹង កម្រិត ៤,៦% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន ចំណែកឯនៅហុងកុង វាកើនដល់ ៣,៨%។ នៅត្រីមាសទី៤ ជប៉ុននៅតែបន្តមានបរិត្តផរណា ដែលបានដាក់សម្ពាធបង្កើនអត្រាការប្រាក់ពិត។

នៅត្រីមាសទី៤ ប្រាក់រៀលឡើងថ្លៃ ១,៦% ធៀបនឹងត្រីមាសមុន (១,៩% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ និង 0,0៤% (0,៨% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុងវៀតណាម។ ប្រាក់យ៉េនជប៉ុន ធ្លាក់ថ្លៃ ៣,៤% ធៀបនឹងត្រីមាសមុន (៤,៥% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៤ ពោត (US No. 2) ធ្លាក់ថ្លៃ ៥,0% (តែឡើងថ្លៃ ១៤,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៣១0,៩ដុល្លារ/តោន សណ្តែកសៀង (US No. 1) ធ្លាក់ថ្លៃ ១១% (ឡើងថ្លៃ ២៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥៧៧,៨ដុល្លារ/តោន ហើយប្រេងម៉ាស៊ូត (low sulphur No. 2) ធ្លាក់ថ្លៃ ១,0% (ឡើងថ្លៃ ៣,៩% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម 0,៨0ដុល្លារ/លីត្រ។ នៅត្រីមាសទី៤ កៅស៊ូ (SMR 5) ឡើងថ្លៃ ៥,១% ធៀបនឹងត្រីមាសមុន (ប៉ុន្តែធ្លាក់ថ្លៃ ១៩,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ២៩៤១,៥ដុល្លារ/តោន, ប្រេងឆៅ (OPEC spot) ចុះថ្លៃ 0,៧% (ឡើងថ្លៃ ៧,២% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១0៧,៣ដុល្លារ/ធុង, ហើយ សាំងឡើងថ្លៃ ២,៥% (៧,២% ធៀបនឹងមួយឆ្នាំមុន) ដល់ 0,៧៣ដុល្លារ/លីត្រ។ នៅត្រីមាសទី៤ អង្ករថៃ (Thai 100% B) ឡើងថ្លៃ 0,២% ធៀបនឹងត្រីមាសមុន ដល់ ៥៩៧ដុល្លារ/តោន ប៉ុន្តែ ចុះថ្លៃ ២,២% ធៀបនឹងមួយឆ្នាំមុន។

---

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

## តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.8 | 0.1 | - | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.5 | 6.5 | 6.5 | 6.3 | 6.4 | 6.2 | 6.1 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.6 | 4.0 | 5.8 | 5.2 | 4.7 | 5.4 | 5.2 | 6.4 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 8.3 | 0.9 | 5.9 | 3.6 | 1.6 | 1.9 | 0.3 | 1.5 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 3.0 | 2.6 | 3.5 | -9.0 | 0.0 | 4.2 | 3.3 | 19.5 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.7 | 5.4 | 5.7 | 7.2 | 6.1 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.7 | 9.5 | 9.1 | 8.9 | 8.1 | 7.6 | 7.4 | 7.9 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 7.2 | 5.1 | 4.3 | 3.0 | 4.2 | 3.6 | 1.3 | 2.5 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 4.2 | 3.4 | 3.4 | 3.4 | 3.0 | 2.4 | 1.5 | 1.6 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 6.5 | 4.9 | 3.4 | 1.9 | 0.4 | -0.2 | 1.0 | 3.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 2.5 | 1.6 | 1.4 | 0.7 | 0.0 | -0.4 | -0.6 | -0.9 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -1.0 | -1.0 | 0.0 | -1.0 | 2.8 | 3.5 | 0.1 | 0.5 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 2.3 | 1.5 | 1.6 | 1.6 | 2.1 | 2.2 | 2.5 | 1.6 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៦-២០១២ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 3.6 | 6.2 | 6.7 | 4.9 | 5.5 | 2.9 | 1.6 | 1.8 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 6.8 | 5.9 | 4.7 | 4.1 | 3.8 | 4.5 | 4.5 | 4.4 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 2.8 | 3.3 | 3.4 | 3.2 | 2.3 | 1.7 | 1.4 | 1.3 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.7 | 5.5 | 5.5 | 4.9 | 5.2 | 4.2 | 4.0 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.0 | 4.1 | 4.1 | 4.0 | 3.4 | 2.6 | 2.9 | 3.2 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 12.8 | 19.4 | 22.5 | 19.8 | 16.0 | 8.6 | 5.6 | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.1 | 5.7 | 6.3 | 4.6 | 3.8 | 2.9 | 1.9 | 2.1 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 4.0 | 5.1 | 6.5 | 5.7 | 5.2 | 4.2 | 3.1 | 3.8 |
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 4.2 | 4.8 | 4.1 | 2.9 | 2.4 | 1.6 | 1.7 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.3 | 1.6 | 1.3 | 1.4 | 1.3 | 1.6 | 3.0 | 1.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.5 | 2.7 | 2.7 | 2.9 | 2.7 | 2.5 | 2.5 | 2.3 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.0 | 0.3 | 0.2 | -0.3 | 0.3 | 0.2 | -0.4 | -0.2 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 2.1 | 3.5 | 3.8 | 3.3 | 2.8 | 1.9 | 1.7 | 1.9 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.2 | 3995.9 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419.0 | 9699.0 | 10413.8 | 9089.9 | 8902.0 | 8593 | 8625.8 | 8985.7 | 9078.6 | 9281.3 | 9490.3 | 9614.6 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 3.1 | 3.0 | 3.0 | 3.2 | 3.1 | 3.1 | 3.1 | 3.1 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.5 | 1.4 | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.6 | 1.2 |
| ថៃ (បាត) | 32.2 | 33.4 | 34.3 | 31.7 | 30.6 | 30.3 | 30.2 | 31.0 | 31.0 | 31.3 | 31.3 | 30.7 |
| វៀតណាម (ដុង) | 16,030.0 | 16,382.0 | 17,725.2 | 19,200.8 | 20,2738 | 20,693.6 | 20,699.6 | 20,997.7 | 20,971.2 | 20849.7 | 20847.5 | 20839.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.0 | 6.9 | 6.8 | 6.76 | 6.6 | 6.5 | 6.4 | 6.36 | 6.3 | 6.3 | 6.4 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.77 | 7.8 | 7.8 | 7.8 | 7.78 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1120.2 | 1084.3 | 1084.9 | 1144.87 | 1131.2 | 1152.6 | 1132.9 | 1089.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.3 | 28.9 | 29.2 | 30.26 | 29.7 | 29.6 | 29.8 | 29.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.7 | 0.7 | 0.74 | 0.8 | 0.8 | 0.8 | 0.8 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 82.3 | 81.7 | 77.9 | 77.78 | 79.3 | 80.1 | 78.6 | 81.3 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

## តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១២ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ពោត (US No. 2) - USA (USD/តោន) | 149.08 | 218.15 | 167.31 | 169.90 | 280.3 | 311.6 | 302.8 | 270.8 | 277.5 | 270.5 | 327.1 | 310.9 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 707.68 | 912.23 | 686.84 | 834.75 | 1251.0 | 1147.0 | 1079.0 | 1024.7 | 1106.7 | 1083.3 | 993.0 | 809.3 |
| កៅស៊ូ SMR 5 (USD/តោន) | 2202.30 | 2586.30 | 1884.84 | 3152.17 | 5278.0 | 4968.8 | 4617.6 | 3658.0 | 3701.2 | 3361.0 | 2799.2 | 2941.5 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.36 | 615.32 | 524.47 | 456.67 | 528.3 | 514.3 | 581.3 | 610.3 | 549.0 | 600.3 | 595.7 | 597.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 294.59 | 460.41 | 414.03 | 375.38 | 537.2 | 525.7 | 514.0 | 454.8 | 490.8 | 546.5 | 649.4 | 577.8 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 69.25 | 95.44 | 60.50 | 71.61 | 100.7 | 113.3 | 108.9 | 109.1 | 117.3 | 106.7 | 106.6 | 107.3 |
| សាំង - US Gulf Coast (សេន/លីត្រ) | 53.58 | 62.22 | 42.91 | 49.83 | 67.9 | 78.7 | 74.6 | 68.5 | 79.0 | 74.0 | 71.6 | 73.4 |
| ម៉ាស៊ូត (ស្តាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.51 | 76.20 | 43.05 | 51.62 | 72.5 | 75.7 | 77.3 | 77.3 | 83.8 | 77.8 | 81.1 | 80.3 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ទោះបីមានការយឺតយ៉ាវក្នុងវិស័យមួយចំនួនក្តី ក៏សេដ្ឋកិច្ចកម្ពុជាជារួម នៅតែមានកំណើនមាំទាំនិងរស់រវើកនៅឆ្នាំ២០១២ ដោយមានអត្រាកំណើនរំពឹងទុកប្រមាណ ៧,៣%។ ទោះយ៉ាងណាក៏ដោយកម្ពុជាត្រូវតែប្រយ័ត្នប្រយែងជានិច្ចឲ្យបាននូវលក្ខណៈប្រកួតប្រជែង នៅចំពោះមុខភាពមិនប្រាកដប្រជា និងភាពងាយរងគ្រោះនៃសេដ្ឋកិច្ចពិភពលោក ជាពិសេសនៅតំបន់អឺរ៉ូ និងសហរដ្ឋអាមេរិក។

នៅត្រីមាសទី៤ ឆ្នាំ២០១២ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កើន ១៦៩,៧% ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ១៣,៦% ធៀបនឹងមួយឆ្នាំមុន មកត្រឹម ១,១ពាន់លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្ម ធ្លាក់ចុះ ៣៦,៧% ធៀបនឹងត្រីមាសមុន (៧៤% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១១៤,៦លានដុល្លារ ទោះបីរដ្ឋាភិបាលកាន់តែយកចិត្តទុកដាក់ប្រឹងលើកកម្ពស់ ភាពប្រកួតប្រជែង និងផលិតភាពក្នុងវិស័យនេះក្តី។ ឧស្សាហកម្មនៅតែជាកម្លាំងចម្បងមួយជំរុញកំណើន ផសស ជាពិសេសការនាំចេញ។ វិនិយោគក្នុងវិស័យនេះកើន ១២,៣% ធៀបនឹងមួយឆ្នាំមុន។ វិនិយោគក្នុងផ្នែកកាត់ដេរសម្លៀកបំពាក់ ដែលជាផលិតផលកម្មន្តសាលចម្បងគេ កើន ៤២,៦% ធៀបនឹងត្រីមាសមុន (២៨,៨% ធៀបនឹងមួយឆ្នាំមុន) ដល់ ១៥២,៩ លានដុល្លារ។ វិស័យទេសចរណ៍ ក៏មានលក្ខណៈរឹងមាំដែរ ដោយបានទាក់ទាញវិនិយោគក្នុងផ្នែកសណ្ឋាគារ និងអាជីវកម្មពាក់ព័ន្ធនឹងទេសចរណ៍ មានតម្លៃសរុប ៦៤០,៦លានដុល្លារ ឬកើន ១៤៩,៣% បើធៀបនឹងមួយឆ្នាំមុន។

វិស័យសំណង់ ជាសសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ច ដែលទទួលរងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុសកល និងមានការរើបឡើងវិញយឺតៗ។ តម្លៃគម្រោងសាងសង់សរុបនៅត្រីមាសទី៤ ធ្លាក់ចុះ ៦៥,៨% ធៀបនឹងត្រីមាសមុន (៥៩,៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥៩,៩លានដុល្លារ ក្នុងនោះ គម្រោងភូមិគ្រឹះនិងផ្ទះធ្លាក់ចុះ៥៣,៦%(៨៦%ធៀបនឹងមួយឆ្នាំមុន)មកត្រឹម ៨,៥លានដុល្លារ គម្រោងផ្ទះល្វែង ធ្លាក់ចុះ ៨៣,៤% (៨២,៦% ធៀបនឹងមួយឆ្នាំមុន)មកត្រឹម១០,២លានដុល្លារ។នៅឆ្នាំ២០១២ មានភ្ញៀវបរទេស ប្រហែល ៣,៥លាននាក់ មកទស្សនាកម្ពុជា ហើយនៅត្រីមាសទី៤ នេះ ចំនួនភ្ញៀវបរទេស កើន ២២,៦% បើធៀបនឹងត្រីមាសមុន (២៦,៣% ធៀបនឹងមួយឆ្នាំមុន)។ ភ្ញៀវទេសចរមកដល់តាមផ្លូវអាកាស កើន ៣៥,១% (១៦,៣% ធៀបនឹងមួយឆ្នាំមុន) រីឯ ភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក កើន ១២,៤% (៣៨,២% ធៀបនឹងមួយឆ្នាំមុន)។

ការនាំចេញនៅតែមាំទាំដដែល ទោះបីមានការឡើងចុះតាមត្រីមាសក្តី។ នៅត្រីមាសទី៤ ការនាំចេញសរុប កើន ៩,៩% ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន ដល់ ១,៤ពាន់លានដុល្លារ។ វិស័យកាត់ដេរ ដែលរួមចំណែក ៧៨,៤% នៃតម្លៃនាំចេញសរុបនោះ បានកើន ១,០% ដល់ ១,១ពាន់លានដុល្លារ ក្នុងនេះមាន ៤០% បាននាំចេញទៅសហរដ្ឋអាមេរិក, ៣៧% ទៅសហភាពអឺរ៉ុប, ០,៨% ទៅបណ្តាប្រទេសអាស៊ាន និង ៣,៧% ទៅជប៉ុន។ ទោះបីការនាំចេញផលិតផលកសិកម្មដែលមានកៅស៊ូ និងស្រូវជាសំខាន់ បានកើន ១៨,២% ធៀបនឹងមួយឆ្នាំមុនក្តី ក៏ចំណែកផលិតផលកសិកម្មនៅក្នុងតម្លៃនាំចេញសរុប នៅមានតិច (៣,០%) បើធៀបនឹងផលិតផលនាំចេញដទៃទៀត។ នៅត្រីមាសទី៤ ការនាំចូលសរុប កើន ១៣,២% ធៀបនឹងមួយឆ្នាំមុន ក្នុងនេះការនាំចូលប្រេងម៉ាស៊ូត កើន ៣២,៦% ការនាំចូលបរិក្ខារសំណង់ កើន ៣៨,៣% រីឯការនាំចូលប្រេងសាំង ធ្លាក់ចុះ ៣,៧%។

## ហិរញ្ញវត្ថុសាធារណៈ

កំណើនមធ្យោបាយសារពើពន្ធ តាមរយៈការពង្រឹងការប្រមូលចំណូល ចាំបាច់ខ្លាំងណាស់ចំពោះរដ្ឋាភិបាល និងសេដ្ឋកិច្ច។ សញ្ញាមួយបង្ហាញពីភាពរីកចម្រើន គឺ កំណើនប្រាក់ចំណូលរដ្ឋាភិបាលពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ចំណូលចរន្តក្នុងទូទាំងឆ្នាំ២០១២។ នៅត្រីមាសទី៤ ចំណូលសរុប កើន ៦,១% ធៀបនឹងត្រីមាសមុន (១៣,៥% ធៀបនឹងមួយឆ្នាំមុន) ដល់ ២០១៧ពាន់លានរៀល។ ចំណូលចរន្ត កើន ១០,៩% (១៤,៥% ធៀបនឹងមួយឆ្នាំមុន) ចំណូលពន្ធ កើន ៥,៦% (១៣,៤% ធៀបនឹងមួយឆ្នាំមុន) ហើយចំណូលមិនមែនពន្ធ កើន ៤៦,២% (២០,៦% ធៀបនឹងមួយឆ្នាំមុន)។ ចំណូលមូលធន ធ្លាក់ចុះ ៧៧,១% (៣៤,៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៣,៩ពាន់លានរៀល ដែលអាចនឹងប៉ះពាល់ដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន។ ការថយចុះចំណាយរដ្ឋាភិបាលនៅត្រីមាសទី៤ ឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងបំបាត់ការខ្ជះខ្ជាយក្នុងចំណាយរបស់រដ្ឋាភិបាល។ ចំណាយសរុប ធ្លាក់ចុះ ៦,៨% ធៀបនឹងត្រីមាសមុន (១១,៧% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៧៥១,៥ពាន់លានរៀល។ ចំណាយមូលធន ធ្លាក់ចុះ ១៤,៨% (២៩,៦% ធៀបនឹងមួយឆ្នាំមុន), ចំណាយលើបៀវត្សរ៍ ធ្លាក់ចុះ ៩,៥% (២,២% ធៀបនឹងមួយឆ្នាំមុន) ហើយ ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច ធ្លាក់ចុះ ៩,០% (១៣,៧% ធៀបនឹងមួយឆ្នាំមុន)។

---

[១] អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី៤ អតិផរណា ស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ដោយធ្លាក់ចុះមកត្រឹម ១,៨% ធៀបនឹង ៤,៩% នៅត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ សន្ទស្សន៍ថ្លៃម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ១,៤% ថ្លៃដឹកជញ្ជូន កើន ១,២% ធៀបនឹងមួយឆ្នាំមុន។ ក្នុងត្រីមាសនេះដែរ ប្រាក់រៀល ឡើងថ្លៃ ១,៦% ធៀបនឹងត្រីមាសមុន (១,៩% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារ។ មាស ឡើងថ្លៃ ៤,១% (១,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ២០៦,៥ដុល្លារ/ជី ប្រេងម៉ាស៊ូត ឡើងថ្លៃ ២,៩% (៤,៥% ធៀបនឹងមួយឆ្នាំមុន) ដល់ ៥១២៩រៀល/លីត្រ ហើយប្រេងសាំង ឡើងថ្លៃ ០,៨% (៣,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ៥២៩៥ រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៣ ទ្រព្យសកម្មបរទេសសុទ្ធ ធ្លាក់ចុះ ០,០៣% ធៀបនឹងត្រីមាសមុន (កើន ៥,៨% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៨.៧២៣,៦ពាន់លានរៀល។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ១០% (៧៥,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ៨៧១៧,២ពាន់លានរៀល។ សាច់ប្រាក់ងាយស្រួលសរុប កើន ២១,១% ធៀបនឹងមួយឆ្នាំមុន រូបិយវត្ថុ កើន ៧,៦% ហើយ រូបិយវត្ថុផ្សេងៗ កើន ២៣,៨%។

## ស្ថានភាពក្រីក្រ

អង្កេតប្រចាំត្រីមាសរបស់វិទ្យាស្ថាន CDRI លើពលករងាយរងគ្រោះ ធ្វើឡើងក្នុងខែកុម្ភៈ បង្ហាញថា មានតែប្រាក់ចំណូលរបស់អ្នកលក់បន្លែតូចតាចប៉ុណ្ណោះ ដែលបានធ្លាក់ចុះ បើធៀបនឹងខែកុម្ភៈឆ្នាំមុន។ ពលករ ៩ក្រុមផ្សេងទៀត មាន អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នករើសអេតចាយ អ្នករត់តុភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មកររោងចក្រកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មានជំនាញ និងគ្មានជំនាញ សុទ្ធតែមានប្រាក់ចំណូលខ្ពស់ជាងមុន។

ប្រាក់ចំណូលមធ្យមប្រចាំថ្ងៃរបស់ អ្នកស៊ីឈ្នួលធ្វើស្រែ កើនក្នុងអត្រាខ្ពស់បំផុត គឺ ២៤% ដល់ ៥៨២៨រៀល ប៉ុន្តែពួកគេប្រើវាអស់ជិត ៥៤% ទៅលើចំណាយប្រចាំថ្ងៃ។ គ្រប់គ្នាក្នុងក្រុមនេះ មានដីដាំដុះតិចជាងបីហិកតា ហើយមាន ៦៨% ប្រាប់ថា ការងារធ្វើស្រែជាប្រភពចំណូលចម្បងរបស់គ្រួសារខ្លួន។

ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៩,៣% ធៀបនឹងកាលពីបីខែមុន ប៉ុន្តែកើន ១៩% ធៀបនឹងមួយឆ្នាំមុន ដល់ ៩៤៨៣រៀល។ របស់អេតចាយ បានធ្លាក់ថ្លៃ រីឯចំនួនអ្នករើសអេតចាយ បានកើនឡើង។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៧០% ប្រាប់ថា បានខ្ចីបុលគេដើម្បីដោះស្រាយចំណាយចិញ្ចឹមជីវិត។ ពួកគេចំណាយអស់ ៦៨% នៃប្រាក់ចំណូលទៅលើការចាយវាយប្រចាំថ្ងៃដោយមិនរាប់បញ្ចូលការបង់ថ្លៃការប្រាក់ និងចំណាយលើការព្យាបាលជំងឺទេ។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែង កើន ៩,៤% ធៀបនឹងបីខែមុន ឬ ១៨% ធៀបនឹងមួយឆ្នាំមុន ដល់ ១២.៧៤៤រៀល។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ ៤០នាក់ មាន ៨៥% បានចាកចេញពីគ្រួសារដើម្បីមកធ្វើការនៅភ្នំពេញ។ ក្នុងចំណោមពលករទាំងនេះ មាន ១០% រស់នៅតាមចិញ្ចើមថ្នល់ ឬនៅតាមវត្ត ហើយអ្នកក្រៅពីនោះ ជួលផ្ទះស្នាក់នៅ។ បន្ទាប់ពីការចាយវាយប្រចាំថ្ងៃ ពួកគេស្ទើរមិនមាននៅសល់លុយសម្រាប់សន្សំទេ។

នៅខែកុម្ភៈ ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុប កើន ១៨% ធៀបនឹងមួយឆ្នាំមុន ឬ ១,១% ធៀបនឹងបីខែមុន ដល់ ១៤.៤២៧ រៀល។ អ្នករត់ម៉ូតូឌុបទាំងនេះ ជាប្រភពប្រាក់ចំណូលចម្បងក្នុងគ្រួសារខ្លួន ហើយបានចេញមកនៅទីក្រុងតែម្នាក់ឯង ក្នុងនេះមាន ៥៨% ត្រូវជួលផ្ទះស្នាក់នៅ, ២៣% មានផ្ទះផ្ទាល់ខ្លួន ហើយក្រៅពីនោះ មកស្នាក់នៅជាមួយសាច់ញាតិ ឬនៅតាមវត្ត។

ប្រាក់ចំណូលរបស់កម្មករសំណង់មានជំនាញ កើន ៩,៦% ធៀបនឹងមួយឆ្នាំមុន ប៉ុន្តែធ្លាក់ចុះ ៤,៤% ធៀបនឹងបីខែមុន។ សកម្មភាពសំណង់បានរីកដុះដាល ប៉ុន្តែចំនួនកម្មករក៏កើនឡើងដែរ។ ទោះយ៉ាងនេះក្តី មាន ៩០% បានគិតថា ខ្លួនមានជីវភាពប្រសើរជាងមុន។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ កើន ១៨% ធៀបនឹងមួយឆ្នាំមុន និង ១៥% ធៀបនឹងបីខែមុន។ ទោះបីជា ៦៨% នៃកម្មករទាំងនេះត្រូវជួលផ្ទះគេស្នាក់នៅក្តី ក៏ពួកគេអាចទ្រទ្រង់ជីវភាពបាននៅទីក្រុងភ្នំពេញ ហើយអាចផ្ញើប្រាក់ខ្លះទៅឲ្យគ្រួសារខ្លួនទៀតផង។

ចំណូលរបស់អ្នកលក់បន្លែតូចតាច កើន ៤៩% ធៀបនឹងបីខែមុន ប៉ុន្តែធ្លាក់ចុះ ១៩% បើធៀបនឹងមួយឆ្នាំមុន មកត្រឹម ៩៩៤៨រៀល។ ពួកគេប្រាប់ថា ចំនួនអ្នកលក់បន្លែបានកើនឡើង ហើយពួកគេមិនអាចពង្រីកអាជីវកម្មរបស់ខ្លួនបានទេ ដោយសារបញ្ហាកង្វះដើមទុន។ ទោះជាយ៉ាងនេះក្តី ពួកគេអាចសន្សំប្រាក់បានមួយចំនួន បន្ទាប់ពីការដោះស្រាយចំណាយប្រចាំថ្ងៃដែលស្មើនឹង ៦៣% នៃប្រាក់ចំណូល។ ពួកគេ មានជីវភាពប្រសើរជាងមុនដោយសាររបរលក់ដូររបស់ខ្លួន។

នៅខែកុម្ភៈ ចំណូលរបស់កម្មកររោងចក្រកាត់ដេរ កើន ៤,៧% ធៀបនឹងបីខែមុន ឬ ១៧% បើធៀបនឹងមួយឆ្នាំមុន ដល់ ១០.០០០រៀល។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ទាំង ១២០នាក់ មាន ៥៥% មានមុខងារខាងដេរ, ១៣% ជាអ្នកត្រួតពិនិត្យគុណភាព ហើយអ្នកក្រៅពីនោះ មិនបានប្រាប់ពីមុខងារខ្លួនទេ។ ពួកគេសន្សំប្រាក់បានជាមធ្យម ២០០.០០០រៀល/ខែ ហើយផ្ញើវាទៅឲ្យក្រុមគ្រួសារ។ កម្មករទាំងនេះប្រាប់ថា ពួកគេធ្វើការជាមធ្យម ៥៨ម៉ោង/សប្តាហ៍ ហើយចង់បានម៉ោងការងារបន្ថែមទៀត ដើម្បីបានចំណូលកាន់តែច្រើន។

# តាមដានសេដ្ឋកិច្ច-សូចនាករ

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៧-១២*

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 135.6 | 92.0 | 615.0 | 530.68 | 4.1 | 156.4 | 123.9 | 440.6 | 154.7 | 81.2 | 181.1 | 114.6 |
| ឧស្សាហកម្ម | 709.1 | 724.9 | 818.5 | 403.66 | 67.1 | 257.1 | 2361.0 | 174.9 | 208.7 | 173.7 | 245.6 | 196.5 |
| *កាត់ដេរ* | *170.7* | *142.8* | *90.1* | *122.81* | *57.1* | *108.4* | *109.7* | *118.7* | *139.4* | *97.5* | *107.2* | *152.9* |
| សេវាកម្ម | 1742.5 | 10,003.2 | 4432.0 | 1337.34 | 209.5 | 2229.2 | 264.1 | 722.6 | 50.9 | 18.0 | 2.1 | 845.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *1048.3* | *8758.1* | *3980.1* | *1105.14* | *107.9* | *2221.9* | *264.1* | *257.0* | *50.9* | *0.0* | *0.0* | *640.6* |
| សរុប | 2587.2 | 10,570.9 | 5865.5 | 2271.7 | 280.2 | 2642.7 | 2748.9 | 1338.1 | 414.4 | 273.0 | 428.8 | 1156.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | -77 | 8.41 | -4 | -51.3 | -69 | -33.9 | 55.6 | 169.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -32 | 308.6 | -44.5 | -61.3 | -24.8 | 643.2 | 753 | 9.6 | 48.4 | -89.6 | -84.4 | -13.6 |

** Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 79.1 | 154.7 | 64.3 | 36.2 | 4.1 | 5.9 | 106.3 | 60.9 | 64.8 | 66.6 | 18.3 | 8.5 |
| ផ្ទះល្វែង | 297.2 | 221.6 | 149.6 | 183.8 | 16.1 | 22.8 | 90.0 | 58.5 | 60.8 | 219.3 | 61.6 | 10.2 |
| ផ្សេងៗ | 259.6 | 740.9 | 227.3 | 269.7 | 23.6 | 48.7 | 51.1 | 29.3 | 197.2 | 47.8 | 94.9 | 41.2 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 43.8 | 77.4 | 247.4 | 148.7 | 322.8 | 333.6 | 174.9 | 59.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 76.7 | 219.7 | -39.9 | 117.1 | 3.3 | -47.6 | -65.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11 | -14.8 | -61.7 | 215.6 | 40.29 | 637.1 | 331.1 | -29.3 | -59.7 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1296.5 | 1239.4 | 1111.7 | 1304.3 | 4.1 | 286.9 | 335.3 | 430.7 | 513.6 | 317.1 | 370.5 | 500.7 |
| តាមផ្លូវគោក និងទឹក | 718.6 | 881.9 | 999.7 | 1094.6 | 16.1 | 319.6 | 364.5 | 366.3 | 481.5 | 424.3 | 450.3 | 506.1 |
| សរុប | 2015.1 | 2121.3 | 2111.5 | 2398.9 | 23.6 | 606.5 | 699.8 | 797.1 | 995.2 | 761.4 | 820.9 | 1006.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -22.1 | 15.4 | 13.9 | 24.9 | -23.5 | 7.8 | 22.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 28.4 | 5.3 | 0.5 | 13.6 | -14.8 | 12.8 | 20.2 | 13.0 | 27.8 | 25.5 | 17.3 | 26.3 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 3050.3 | 3097.8 | 2901.6 | 3630.2 | 1017.7 | 1132 | 1455.6 | 1324.2 | 1280.1 | 1775.9 | 1595.8 | 1454.7 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2938.9 | 2986.2 | 2565.3 | 3223.4 | 880.48 | 964.15 | 1285.71 | 1129.23 | 1070.8 | 1474.7 | 1329.1 | 1140.83 |
| *- សហរដ្ឋអាមេរិក* | 1956.5 | 1908.3 | 1512.6 | 1853.9 | 464.47 | 466.7 | 619.38 | 504.71 | 493.3 | 627.3 | 566.6 | 456.07 |
| *- សហភាពអឺរ៉ុប* | 654.3 | 689.0 | 644.7 | 809.5 | 232.0 | 301.4 | 397.5 | 391.3 | 328.4 | 504.1 | 462.7 | 421.82 |
| *- អាស៊ាន* | 3.2 | 10.76 | 6.9 | 9.9 | 3.77 | 4.18 | 4.73 | 4.95 | 6.4 | 11.7 | 11.4 | 9.76 |
| *- ជប៉ុន* | 28.5 | 25.2 | 44.5 | 86.5 | 34.3 | 28 | 43.4 | 41.25 | 50.1 | 48.9 | 47.1 | 42.47 |
| *- ប្រទេសផ្សេងៗ* | 296.4 | 352.9 | 356.5 | 463.6 | 145.9 | 163.89 | 220.68 | 187.03 | 192.5 | 282.7 | 241.3 | 210.71 |
| កសិកម្ម | 55.7 | 44.5 | 73.1 | 164.9 | 74.01 | 97.07 | 98.91 | 92.06 | 80.5 | 101.3 | 86.1 | 108.77 |
| *- កៅស៊ូ* | 41.0 | 35.8 | 51.6 | 89.1 | 49.86 | 48.6 | 56.11 | 43.06 | 40.3 | 46.4 | 46.1 | 43.84 |
| *- ឈើ* | 8.7 | 3.4 | 3.5 | 34.1 | 6.2 | 16.8 | 16.1 | 9.7 | 8.9 | 12.4 | 4.1 | 11.6 |
| *- ត្រី* | 3.2 | 2.3 | 3.9 | 2.8 | 0.6 | 0.4 | 1.4 | 0.7 | 0.5 | 0.7 | 0.4 | 0.4 |
| *- អង្កុរ* | 1.5 | 2.6 | 10.9 | 34.7 | 16.9 | 30.3 | 22.4 | 37.0 | 27.1 | 37.531.7 | | 50.2 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 1.2 | 0.5 | 3.0 | 4.1 | 0.5 | 1.0 | 2.9 | 1.6 | 3.9 | 4.4 | 3.9 | 2.8 |
| ផ្សេងៗ | 55.8 | 67.1 | 263.22 | 242.0 | 63.2 | 70.8 | 71.0 | 102.9 | 128.8 | 199.9 | 180.6 | 205.1 |
| ការនាំចូលសរុប | 3770.2 | 4272.5 | 4331.5 | 5190.6 | 1454.9 | 1690.1 | 1519.1 | 1711.9 | 1609.2 | 1885.4 | 2015.2 | 1938.2 |
| ក្នុងនេះ៖ សាំង | 73.6 | 84.8 | 91.13 | 108.6 | 62.2 | 76.7 | 73.8 | 81.8 | 70.7 | 76.7 | 78.0 | 78.8 |
| ម៉ាស៊ូត | 133.7 | 119.5 | 180.67 | 203.8 | 92.7 | 129.9 | 118.9 | 105.5 | 139.4 | 126.6 | 138.3 | 139.9 |
| សម្ភារៈសំណង់ | 44.31 | 56.3 | 49.74 | 57.6 | 11.8 | 12.7 | 11.6 | 12.0 | 13.5 | 14.1 | 16.5 | 16.6 |
| ផ្សេងៗ | 3518.5 | 4011.8 | 4010 | 4820.6 | 1288 | 1471 | 1315 | 1513 | 1386 | 1668.0 | 1782.4 | 1703.0 |
| ជញ្ជីងពាណិជ្ជកម្ម | -719.9 | -1174.7 | -1429.9 | -1560.5 | -437.2 | -558.1 | -63.5 | -387.6 | -329.1 | -642.2 | -419.4 | -483.6 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | -6.6 | 9.5 | 33.4 | -12.2 | -5.2 | -37.7 | -9.9 | -14.2 |
| ការនាំចេញសរុប | - | - | - | - | -4.9 | 11.2 | 28.6 | -9.0 | -3.3 | 38.7 | -10.1 | -8.8 |
| ការនាំចូលសរុប | - | - | - | - | 8.9 | 16.2 | -10.1 | 12.7 | -6.0 | 17.2 | 6.9 | -3.8 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 8.9 | 1.6 | -14.1 | 25.7 | 40.8 | 34.5 | 37.0 | 19.8 | 21.6 | 53.0 | 3.4 | 1.0 |
| ការនាំចេញសរុប | 8.5 | 1.6 | -6.3 | 25.1 | 46.7 | 37.9 | 39.3 | 23.7 | 25.8 | 56.9 | 9.6 | 9.9 |
| ការនាំចូលសរុប | 23.7 | 13.3 | 1.4 | 19.8 | 30.1 | 33.7 | 3.2 | 28.1 | 10.6 | 11.6 | 32.7 | 13.2 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site)*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៧-១២ (ពាន់លានរៀល)

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 1146.1 | 5290.0 | 5988.99 | 2805.83 | 1400.46 | 1564.25 | 1510.1 | 1776.61 | 1728.9 | 2045.1 | 1900.8 | 2017.0 |
| ចំណូលចរន្ត | 1141.6 | 5210.7 | 5859.08 | 2786.12 | 1378.61 | 1563.01 | 1497.59 | 1740.12 | 1725.8 | 1928.6 | 1796.4 | 1993.1 |
| ចំណូលពន្ធ | 965.2 | 4409.9 | 4692.96 | 2457.02 | 1142.29 | 1367.52 | 1313.35 | 1454.33 | 1403.82 | 1721.8 | 1560.7 | 1648.5 |
| ពន្ធក្នុងស្រុក | 661.8 | 3248.4 | 3533.57 | 1727.10 | 875.569 | 1095.26 | 996.642 | 1104.12 | 1092.27 | 1403.4 | 1230.0 | 1277.2 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 303.5 | 1161.5 | 1159.39 | 639.00 | 266.719 | 272.27 | 316.709 | 350.207 | 311.253 | 318.4 | 330.7 | 371.4 |
| ចំណូលមិនមែនពន្ធ | 176.4 | 800.8 | 1166.13 | 507.13 | 236.329 | 195.48 | 184.23 | 285.8 | 330.98 | 206.9 | 235.7 | 344.6 |
| ចំណូលលើទ្រព្យសម្បត្តិ | 13.6 | 78.0 | 291.13 | 4.87 | 10.6426 | 18.64 | 15.19 | 19.35 | 91.28 | 13.1 | 22.5 | 16.2 |
| លក់ទំនិញ និងសេវា | 124.3 | 424.7 | 460.07 | 268.08 | 129.982 | 138.92 | 144.192 | 175.627 | 166.899 | 171.4 | 132.8 | 196.3 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 38.5 | 298.2 | 408.91 | 391.70 | 95.7053 | 37.9 | 24.856 | 90.815 | 63.8 | 22.4 | 80.5 | 132.1 |
| ចំណូលជាមូលធន | 4.5 | 79.3 | 129.92 | 2019.39 | 21.8524 | 1.25 | 12.513 | 36.486 | 3.148 | 116.4 | 104.4 | 23.9 |
| ចំណាយសរុប | 1689.7 | 6297.8 | 8784.65 | 4259.67 | 1581.62 | 2025.15 | 2310.61 | 3115.05 | 1688.33 | 2425.6 | 2951.3 | 2751.5 |
| ចំណាយជាមូលធន | 807.4 | 2574.4 | 2853.23 | 1495.19 | 579.818 | 721.01 | 801.167 | 1444.89 | 699.937 | 716.2 | 1194.5 | 1017.7 |
| ចំណាយចរន្ត | 882.3 | 3809.0 | 4773.07 | 2848.81 | 857.492 | 1304.13 | 1509.44 | 1670.15 | 988.398 | 1709.4 | 1756.7 | 1733.9 |
| បៀវត្សរ៍ | 362.6 | 1397.0 | 2048.81 | 1208.81 | 401.0 | 531.6 | 629.697 | 608.253 | 508.919 | 725.2 | 657.5 | 595.0 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 194.2 | 927.1 | 1099.42 | 613.31 | 257.356 | 450.85 | 323.282 | 487.345 | 189.594 | 514.6 | 462.1 | 420.5 |
| ចំណាយចរន្តផ្សេងទៀត | 325.5 | 1384.9 | 1624.84 | 1067.07 | 199.1 | 321.7 | 556.5 | 574.6 | 289.9 | 469.7 | 637.1 | 718.4 |
| សមតុល្យជាទូទៅ | -543.6 | -1007.8 | -2795.66 | -1453.83 | -181.2 | -460.9 | -800.5 | -1,338.4 | 196.5 | -380.6 | -1050.5 | -734.5 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 741.5 | 2055.10 | 1845.21 | 772.81 | 544.4 | 576.9 | 272.9 | 985.0 | 577.8 | 491.5 | 959.3 | 429.2 |
| ហិរញ្ញប្បទានក្នុងស្រុក | -185.8 | -127.00 | 938.64 | 567.96 | -1,745.2 | 238.7 | 312.5 | 105.6 | -565.7 | 148.4 | 22.1 | 62.4 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៧-១២

| | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 19.7 | -0.7 | 4.1 | 3.6 | 6.3 | 6.7 | 4.9 | 2.9 | 2.9 | 1.6 | 1.8 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 9.9 | 33.1 | -0.3 | 4.4 | 3.9 | 7.6 | 8.2 | 6.2 | 3.4 | 3.4 | 1.3 | 1.4 |
| - ដឹកជញ្ជូន | 5.8 | 19.4 | -10.7 | 7.0 | 5.0 | 7.3 | 8.8 | 6.3 | 3.0 | 3.0 | 1.1 | 1.2 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4062.7 | 4058.2 | 4140.5 | 4187.1 | 4041.9 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.7 | 3995.9 |
| រៀលក្នុង ១ បាតថៃ | 122.8 | 123.5 | 121.1 | 133.13 | 132.7 | 133.8 | 135.2 | 131.1 | 130.2 | 129.0 | 129.3 | 131.3 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.0 | 24.8 | 23.4 | 21.725 | 19.9 | 19.6 | 19.8 | 19.4 | 19.3 | 19.4 | 19.5 | 19.2 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 83.2 | 105.9 | 113.1 | 147.58 | 147.9 | 181.5 | 204.6 | 203.8 | 204.1 | 194.5 | 198.3 | 206.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3262.3 | 4555.2 | 3170.9 | 3859.3 | 4427.2 | 4784.6 | 4924.5 | 4908.3 | 5193.9 | 4458.3 | 4983.9 | 5128.8 |
| ថ្លៃសាំង (រៀល/លីត្រ) | 4005.0 | 4750.8 | 3593.1 | 4368.1 | 4750.1 | 5065.5 | 5248.4 | 5113.8 | 5395.8 | 5308.3 | 5251.3 | 5295.4 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៦-១២ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | | | | 2012 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17,079.1 | 18,099.9 | 17,695.2 | 17,893.9 | 18,652.3 | 18,729.6 | 18,723.6 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -282.0 | 576.0 | 1513.3 | 1573.0 | 2778.9 | 3199.2 | 3907.7 | 4961.6 | 5760.8 | 6211.2 | 7922.3 | 8717.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -953.0 | -1816.0 | -2987.0 | -2252.0 | -2126.6 | -2252.7 | -2184.2 | -1925.8 | -2123.1 | -2542.4 | -2399.9 | -2534.2 |
| ឥណទានដល់ផ្នែកឯកជន | 3630.0 | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 13,909.0 | 15,290.6 | 16,385.7 | 17,552.8 | 18,789.0 | 20,081.4 | 21658 |
| រូបិយវត្ថុទូទៅ M2 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 20,278.3 | 22,007.6 | 22,656.8 | 23,654.7 | 24,863.5 | 26,651.9 | 27,440.8 |
| រូបិយវត្ថុ M1 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3497.2 | 3539.8 | 3681.3 | 3956.2 | 3984.6 | 3871.8 | 3861.7 |
| រូបិយវត្ថុផ្សេងៗ | 5285.0 | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 16,781.1 | 18,467.8 | 18,975.5 | 19,698.5 | 20,878.9 | 22,780.1 | 23,579 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 38.1 | 62.9 | 4.8 | 36.9 | 20.0 | 17.7 | 20.5 | 20.0 | 21.5 | 20.2 | 21.1 | 21.2 |
| រូបិយវត្ថុ M1 | 25.3 | 23.8 | 16.9 | 30.1 | 3.2 | 11.1 | 13.6 | 20.2 | 22.8 | 11.4 | 9.4 | 7.6 |
| រូបិយវត្ថុផ្សេងៗ | 42.8 | 75.2 | 2.2 | 38.6 | 24.0 | 19.1 | 21.9 | 19.9 | 21.2 | 22.0 | 23.4 | 23.8 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | 2012 | | 2013 |
| | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 12628 | 8091 | 9055 | 9532 | 9380 | 10,686 | 10,690 | 10,454 | 9588 | 8.6 | 12.5 | 2.2 |
| អ្នកលីសែង | 9005 | 9549 | 9964 | 10,785 | 10,804 | 12,713 | 12,479 | 12,574 | 2,744 | 18.5 | 9.4 | 18.0 |
| អ្នកលក់បន្លែតូចតាច | 9926 | 8273 | 8266 | 8337 | 12,292 | 9901 | 10,347 | 10,542 | 9949 | 22.4 | 49.0 | -19.1 |
| អ្នករើសអេតចាយ | 4652 | 5857 | 6698 | 8388 | 7986 | 8266 | 9139 | 9328 | 9483 | 20.2 | -9.3 | 18.7 |
| អ្នកបម្រើគុភោជនីយដ្ឋាន* | 4327 | 4646 | 5607 | 5986 | 6179 | 6261 | 5569 | 6436 | 6527 | 2.3 | 3.2 | 5.6 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8697 | 6197 | 5691 | 5695 | 4690 | 6431 | 8483 | 5000 | 5828 | 14.8 | 9.9 | 23.8 |
| កម្មកររោងចក្រកាត់ដេរ | 6554 | 7085 | 7746 | 8409 | 8555 | 8391 | 9599 | 8989 | 10,000 | 9.8 | 4.7 | 16.9 |
| អ្នករត់ម៉ូតូឌុប | 15,691 | 10,685 | 10,623 | 11,568 | 12,256 | 13,616 | 12,807 | 13,042 | 14,427 | 14.2 | 1.1 | 17.7 |
| កម្មករសំណង់គ្មានជំនាញ | 8779 | 8343 | 8790 | 10,307 | 10,658 | 11,589 | 10,690 | 11,375 | 12,548 | 1.0 | 15.4 | 17.7 |
| កម្មករសំណង់មានជំនាញ | 12,710 | 12,487 | 11,952 | 13,159 | 13,824 | 12,847 | 14,029 | 14,270 | 15,156 | 10.0 | -4.4 | 9.6 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers, unskilled construction workers and skilled construction workers began in February 2000. Source: CDRI*